**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧១...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្តារ និងរៀបចំកែលំអកំណាត់ដងស្ទឹងសៀមរាប

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**<u>សំ រេ ច</u>**

**ប្រការ ១ .—**

ត្រូវបានបង្កើតគណៈកម្មការស្តារ និងរៀបចំកែលំអកំណាត់ដងស្ទឹងសៀមរាប ខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាប្រធាន

២- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាអនុប្រធាន

៣- ឯកឧត្តម **អ៊ុង អឿន** អភិបាលរងទី ១ ខេត្តសៀមរាប ជាអនុប្រធានអចិន្ត្រៃយ៍

៤- ឯកឧត្តម **ឌុច ចនឌីតូ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

ជាសមាជិក

៥-ឯកឧត្តម ម៉ិន ម៉ាន់ អគ្គនាយកបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម ជាសមាជិក

៦-ឯកឧត្តម ម៉ិន ណារិទ្ធ ប្រធានអគ្គនាយក អាជ្ញាធរ អប្សរា ជាសមាជិក

៧-ឯកឧត្តម គោស៊ុំ សារៈឿន អគ្គនាយក នៃក្រសួងទេសចរណ៍ ជាសមាជិក

ប្រការ ២.—

គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ ពិនិត្យលើទិដ្ឋភាពបច្ចេកទេសលំអិត ដើម្បីស្តារបាតស្ទឹងសៀមរាប ខេត្តសៀមរាប កំណាត់ស្ទឹងចាប់ពីស្ពានអប្សរាហូតដល់សំណង់ស្ទាក់ទឹកអាងក្រពើដោយផ្អែកលើឯកសារសិក្សាដែលមានស្រាប់របស់អាជ្ញាធរអប្សរា ។

-រៀបចំកែលំអមាត់ស្ទឹងទាំងជើងទេរ និងទាំងខ្នងរាប ទាំងសងខាង ឱ្យទៅជាសួនឧទ្យានសាធារណៈ ។

-លើកគំរោងស្តារបាតស្ទឹង គំរោងកែលំអសួនលំហែមាត់ស្ទឹងទាំងសងខាង ដើម្បីដាក់ជូន រាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-តាមដាន និងត្រួតពិនិត្យការអនុវត្តន៍គំរោង

ប្រការ ៣.—

គណៈកម្មការនេះមានអនុគណៈកម្មការជំនួយការចំនួន ២ គឺ :

**ក/ អនុគណៈកម្មការបច្ចេកទេស** : មានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ឌុច ទនធិត្ធ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

២-លោក **លឹម ទាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធាន

៣-លោក **សែ សាមុត** ប្រធាននាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធាន

៤-លោក **ពៅ សុខឃៀង** អនុប្រធានមន្ទីរ ដនសស.ទទួលបន្ទុកការងារសុរិយោដី ខេត្តសៀមរាប ជាសមាជិកអចិន្ត្រៃយ៍

៥-លោក **សន គឹមសៀ** ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប ជាសមាជិក

៦-លោក **ចេង ផល** ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប ជាសមាជិក

៧-លោក **ភង ចន្ទ្រា** អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប ជាសមាជិក

៨-មន្ត្រីជំនាញក្រសួង ដនសស.មួយចំនួនតាមការចាំបាច់ ជាសមាជិក

ខ/ អនុគណៈកម្មការពិគ្រោះ និងផ្ដត់ផ្គង់ : មានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាប្រធាន

២-ឯកឧត្តម គោស៊ុំ សារឿត អគ្គនាយក នៃក្រសួងទេសចរណ៍ ជាអនុប្រធាន

៣-លោក ជា តន្ត្រី នាយខុទ្ទកាល័យសាលាខេត្តសៀមរាប ជាសមាជិក

៤-លោក នូ ផល្លា អភិបាលស្រុកសៀមរាប ជាសមាជិក

៥-លោក កុយ សង ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប ជាសមាជិក

៦-លោក ណាម ពិសិដ្ឋ ប្រធានមន្ទីរហិរញ្ញវត្ថុ ខេត្តសៀមរាប ជាសមាជិក

**ប្រការ ៤.—**

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់និងត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលលើលទ្ធផលការងាររបស់ខ្លួន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រាររបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្នុងការចេញលិខិតផ្លូវការនានា ។

**ប្រការ ៥.—**

គណៈកម្មការនេះត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៦.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី ក្រសួងបរិស្ថាន រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន អភិបាលខេត្តសៀមរាប និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានី ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
-ដូចប្រការ ៦
-ឯកសារ-កាលប្បវត្តិ